ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ. ធ.ជ.០១៩...១៩៧ ឥ.ផ.ហ

ថ្ងៃអង្គារ ៧កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃ
## ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី៣០

ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាបថា ប្រតិបត្តិការ LPCO លើកទី៣០ ដែលមានឥណប្រតិទាន ៩១ថ្ងៃ ១៨២ថ្ងៃ និង ៣៦៤ថ្ងៃ នឹងដាក់ឱ្យដេញថ្លៃនៅថ្ងៃអង្គារ ១៤កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩។ ព័ត៌មានលម្អិតពាក់ព័ន្ធនឹងទំហំទឹកប្រាក់ដេញថ្លៃមានដូចតទៅ៖

| ប្រភេទ LPCO | ទឹកប្រាក់ដាក់ឱ្យដេញថ្លៃ | ទឹកប្រាក់ដេញថ្លៃអតិបរមា |
|---|---|---|
| ៩១ថ្ងៃ | ៧០.០០០.០០០.០០០ (ចិតសិបប៊ីលាន)រៀល | មិនកំណត់ |
| ១៨២ថ្ងៃ | ៥០.០០០.០០០.០០០ (ហាសិបប៊ីលាន) រៀល | មិនកំណត់ |
| ៣៦៤ថ្ងៃ | ៨០.០០០.០០០.០០០ (ប៉ែតសិបប៊ីលាន) រៀល | មិនកំណត់ |

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុទាំងអស់ជ្រាប និងត្រៀមលក្ខណៈចូលរួមការដេញថ្លៃតាមកាលបរិច្ឆេទខាងលើ តាមការគួរ។

សូមទំនាក់ទំនង៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៩៦៣
(៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨)
សារអេឡិចត្រូនិក : lpco_info@nbc.org.kh